ត្រូវការជំនួយ ជាមួយនឹងតម្លៃអ៊ីនធឺណិត?

King County

Seattle

EMERGENCY BROADBAND BENEFIT

តើវាជាអ្វី?

កម្មវិធីជាតិស្តីពី គណៈកម្មការប្រៃស្រ័យទាក់ទងសហព័ន្ធ (Federal Communications Commission, FCC) បណ្តោះអាសន្ន ដើម្បីជួយក្រុមគ្រួសារដែលកំពុង ជួបការលំបាកក្នុងការបង់ថ្លៃសេវាកម្មអ៊ីនធឺណិតអំឡុងការរាតត្បាតនៃជំងឺ។

អត្ថប្រយោជន៍ផ្តល់ជូននូវ៖

- ការបញ្ចុះតម្លៃរហូតដល់ទៅ $50/ខែ សម្រាប់សេវាកម្មអ៊ីនធឺណិត
- ការបញ្ចុះតម្លៃរហូតដល់ទៅ $75/ខែ សម្រាប់គ្រួសារដែលរស់នៅលើដីកុលសម្ព័ន្ធដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និង
- ការបញ្ចុះតម្លៃមួយលើករហូតដល់ទៅ100$សម្រាប់កុំព្យូទ័រយួរដៃកុំព្យូទ័រលើតុឬថែបប្លែតដែលបានទិញតាមរយៈអ្នកផ្តល់សេវាមួយចំនួនដែលចូលរួម។



តើនរណាមានសិទ្ធិទទួលបាន?

គ្រួសារមានសិទ្ធិទទួលបាន ប្រសិនបើសមាជិកម្នាក់ក្នុងគ្រួសារ៖

- មានចំណូលដែលស្ថិតនៅ ឬក្រោម 135% នៃគោលការណ៍ណែនាំអំពីភាពក្រីក្ររបស់សហព័ន្ធ (Federal Poverty Guidelines) ឬចូលរួមនៅក្នុងកម្មវិធីជំនួយមួយចំនួនរបស់រដ្ឋាភិបាល។
- ទទួលអត្ថប្រយោជន៍ក្រោមកម្មវិធីអាហារពេលព្រឹក ឬអាហារពេលថ្ងៃនៅសាលាដែលត្រូវបានកាត់បន្ថយតម្លៃនិងឥតគិតថ្លៃ
- បានទទួលសម្បទានឥតសំណង Pell របស់សហព័ន្ធអំឡុងឆ្នាំផ្តល់រង្វាន់បច្ចុប្បន្ន
- បានជួបប្រទះការបាត់បង់ចំណូលដ៏ច្រើនដោយសារការបាត់បង់ការងារ ឬការឈប់សម្រាកវិស្សមកាលតាំងពីថ្ងៃទី 29 ខែកុម្ភៈ ឆ្នាំ 2020 ឬ
- ត្រូវតាមលក្ខណៈវិនិច្ឆ័យលើសិទ្ធិទទួលបានសម្រាប់កម្មវិធីជំងឺ COVID-19ឬកម្មវិធីចំណូលទាបដែលមានស្រាប់របស់អ្នកផ្តល់សេវាដែលចូលរួម។

របៀបដាក់ពាក្យស្នើសុំ

1. ផ្ទៀងផ្ទាត់សិទ្ធិទទួលបាននៅគេហទំព័រ **GetEmergencyBroadband.org**
2. ទាក់ទងអ្នកផ្តល់សេវាអ៊ីនធឺណិតដែលចូលរួមដើម្បីចុះឈ្មោះនិងប្រើប្រាស់ការបញ្ចុះតម្លៃ។

មានសេវាកម្មអ៊ីនធឺណិត ឬខ្សែជីវិតចំណូលទាបរួចហើយឬ?

សួរអ្នកផ្តល់សេវាអ៊ីនធឺណិតរបស់អ្នកថាតើអ្នកអាចចុះឈ្មោះដោយផ្ទាល់ដើម្បីប្រើប្រាស់ការបញ្ចុះតម្លៃដែរឬទេ។
ដំបូន្មាន៖ ហៅទូរសព្ទទៅលេខនៅលើវិក្កយបត្ររបស់អ្នក ឬស្វែងកឈ្មោះក្រុមហ៊ុន និងអត្ថប្រយោជន៍អ៊ីនធឺណិតនៅពេលមានអាសន្ន *(Emergency Broadband Benefits, EBB)* ។

តើនរណាដែលផ្តល់ជូននូវការបញ្ចុះតម្លៃ?

រកមើលថាតើអ្នកផ្តល់សេវាអ៊ីនធឺណិតណាខ្លះដែលកំពុងចូលរួម នៅគេហទំព័រ **fcc.gov//emergency-broadband-benefit-providers**

KC DCE: 11553w

សម្រាប់ជំនួយ និងព័ត៌មានបន្ថែម សូមចូលទៅគេហទំព័រ GetEmergencyBroadband.org ឬទូរសព្ទទៅលេខ 833-511-0311 ។